# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ០៥១/១៤ គ.ជ.ប ស.ស.រ

# សេចក្ដីសម្រេច

## ស្ដីពី

## ការលុបឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក អាណត្តិទី២ ឆ្នាំ២០១៤

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១២/៩៤៥ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១២ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានសេចក្ដីសម្រេចស្ដីពីការទទួលស្គាល់ជាផ្លូវការ លើការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
- បានឃើញបញ្ជីផ្លូវការបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុករបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តចំនួន ០៥
- យោងស្មារតីអង្គប្រជុំ គ.ជ.ប ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤

## សម្រេច

**ប្រការ ១ :** លុបឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ចំនួន ០៥ នាក់ ដែលមានអាយុមិនគ្រប់ ២៥ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត ដូចមានភ្ជាប់ក្នុងតារាងឧបសម្ព័ន្ធ។

**ប្រការ ២ :** គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាព។

**ប្រការ ៣ :** សេចក្ដីសម្រេចនេះ មានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**អ៊ឹម សួស្ដី**

**ចម្លងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- បណ្ណសារដ្ឋានជាតិ
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### ឧបសម្ព័ន្ធបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក
### អាណត្តិទី២ ឆ្នាំ២០១៤ ដែលមានអាយុមិនគ្រប់ ២៥ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត

| គណបក្ស | ខេត្ត | បេក្ខជនក្រុមប្រឹក្សា | | លេខរៀង | | ឈ្មោះ | ភេទ | ថ្ងៃខែឆ្នាំកំណើត |
|---|---|---|---|---|---|---|---|---|
| | | ក្រុង | ស្រុក | ពេញសិទ្ធិ | បម្រុង | | | |
| ហ្វ៊ុនស៊ិនប៉ិច | បន្ទាយមានជ័យ | សិរីសោភ័ណ | | ៥ | | សំ រាត្រី | ប្រុស | ១៣-១២-១៩៨៩ |
| ប្រជាជនកម្ពុជា | បាត់ដំបង | | ភ្នំព្រឹក | | ៦ | ឈន វិបឿន | ស្រី | ១៣-០៦-១៩៨៩ |
| សង្គ្រោះជាតិ | ក្រចេះ | | ស្នួល | | ១១ | ឌីន សុផៃ | ប្រុស | ២៥-០៥-១៩៨៩ |
| សង្គ្រោះជាតិ | ព្រះវិហារ | | សង្គមថ្មី | | ៨ | អ៊ុន ស៊ីម៉ោល | ស្រី | ០២-០៧-១៩៩១ |
| សង្គ្រោះជាតិ | ពោធិ៍សាត់ | ពោធិ៍សាត់ | | | ១៥ | ថោង ស្រី | ស្រី | ១៥-០៤-១៩៩១ |

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤